# ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៥៤ សសរ

## ស្តីពីការបន្ថែមសមាសភាពសមាជិកគណៈកម្មការសំរាប់

## ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ០៧/សសរ/ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា
- យោងតាមតម្រូវការរបស់គណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

### សំរេច

ប្រការ ១ : ត្រូវបានបន្ថែមសមាសភាពគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់សញ្ញា ដែលមានរាយនាមដូចខាងក្រោម ៖

១- ឯកឧត្តម ពៅ យ៉ាដា អនុរដ្ឋលេខាធិការ ក្រសួងពត៌មាន សមាជិក

២- ឯកឧត្តម អ៊ុំ ម៉ិនធឿន អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ សមាជិក

៣- ឧត្តមសេនីយ៍ត្រី សុខ ផល ប្រធាននាយកដ្ឋានពត៌មានទូទៅ នៃក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២ : សមាជិកគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន ។

ប្រការ ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ក្រសួងពត៌មាន ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ គ្រប់ក្រសួងស្ថាប័ន សាលាខេត្ត-ក្រុង ដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★ ★ ★